# កម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៦៧

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មរបស់សាក្សីជំនាញមួយរូប និងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ស្តីពីបទប្បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍ ហើយក៏បានស្តាប់សក្ខីកម្មរបស់សាក្សីមួយរូប ស្តីពីមន្ទីរសន្តិសុខ ស-២១ ។ ជាដំបូង កញ្ញា **កាស៊ូមិ ណាកាហ្គាវ៉ា** (Kasumi Nakagawa) បានផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញក្នុងរយៈពេលពីរថ្ងៃ ស្តីពីបទប្បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍ និងអំពើហិង្សាលើផ្លូវភេទ និងយេនឌ័រ នៅក្នុងប្រទេសកម្ពុជា នៅមុន ក្នុងអំឡុងពេល និងក្រោយពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។[1] នៅថ្ងៃ

[1] សាក្សីជំនាញ ត្រូវបានស្នើសុំឲ្យផ្តល់នូវការយល់ដឹង និងការបំភ្លឺលើបញ្ហាជាក់លាក់ ជុំវិញលក្ខណៈបច្ចេកទេសដែលចាត់ទុកថាជាការចាំបាច់ចំពោះកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ (សូមមើល វិធាន ៣១(១) នៃវិធានផ្ទៃក្នុង)។ អ្នកជំនាញ ត្រូវបានតែងតាំងតាមរយៈដីការបស់តុលាការដែលបញ្ជាក់ពីកាតព្វកិច្ចជាក់លាក់ (សូមមើល វិធាន ៣១(៣) នៃវិធានផ្ទៃក្នុង)។ អង្គជំនុំជម្រះបានសម្រេចថា តួនាទីរបស់សាក្សីជំនាញ គឺជួយបំភ្លឺដល់អង្គជំនុំជម្រះចំពោះបញ្ហាជាក់លាក់នៃលក្ខណៈបច្ចេកទេស ដែលទាមទារឲ្យមានចំណេះដឹងពិសេសក្នុងវិស័យជាក់លាក់មួយ។ អ្នកជំនាញ មានសិទ្ធិផ្តល់មតិផ្ទាល់ខ្លួន និងអាចផ្តល់ចម្លើយសន្និដ្ឋាន ល្គឹកណាមានការផ្តល់ព័ត៌មានផ្តល់ពាក់ព័ន្ធនឹងការយល់ដឹងទូលាយរបស់អ្នកជំនាញលើប្រធានបទណាមួយ (សូមមើល ឯកសាររបស់អង្គជំនុំជម្រះសាលាដំបូង "សេចក្តីសម្រេច ស្តីពីការចាត់តាំងអ្នកជំនាញ" (ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២) ឯកសារលេខ E215 [ចាប់ពីពេលនេះទៅ ហៅថា **សេចក្តីសម្រេចលើអ្នកជំនាញ**]។ ទោះបីជាយ៉ាងណាក្តី សេចក្តីសម្រេចបានកំណត់ថា "សាក្សីជំនាញ មិនអាចបញ្ចេញមតិយោប់លើបញ្ហាចាំបាច់ក្នុងកំណត់ការពិត ដោយសារតែ មានតែអង្គជំនុំជម្រះផ្តាច់មុខម្នាក់គត់ មានសមត្ថកិច្ចកំណត់យុត្តាធិការលើបញ្ហាក្នុងសំណុំរឿងនេះ។" សេចក្តីសម្រេចនាខែកក្កដា ឆ្នាំ២០១២ បានយោងទៅលើ យុត្តិសាស្ត្រអន្តរជាតិ (សម្រាប់ឧទាហរណ៍ សូមមើល ឯកសាររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង **រដ្ឋអាជ្ញា តទល់ ការេមេរ៉ា** (*Prosecutor v. Karemera*) សេចក្តីសម្រេចស្តីពី សំណើរបស់លោក **យ៉ូសែហ្វ ស្សីរូរេរ៉ា** (Joseph Nzirorera) ស្នើសុំឲ្យមានការ កំណត់វិសាលភាពនៃសក្ខីកម្មរបស់សាក្សីជំនាញគឺ **អាលីស៊ុន ដេស ហ្វហ្គេស** (Alison Des

ពុធ អង្គជំនុំជម្រះសាលាដំបូងបានបែរមកផ្នែកជំនុំជម្រះស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ហើយក៏បានស្តាប់សក្ខីកម្មរបស់សាក្សី **នឹម អ៊ឹម** ដែលត្រូវបានស្នើសុំកោះហៅដោយក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ លោក **នួន ជា** ។ សាក្សី លោក **នឹម អ៊ឹម** បានបម្រើការជាអតីតប្រធានអង្គភាពថតរូប នៅក្នុងមន្ទីរសន្តិសុខ ស-២១ ហើយគាត់អាចរៀបរាប់ពីវិធីនៃការផលិតរូបភាពរបស់អ្នកទោស។ នៅចុងបញ្ចប់នៅសប្តាហ៍នេះ ដើមបណ្តឹងរដ្ឋប្បវេណី **មុំ វុន** បានផ្តល់សក្ខីកម្មអំពីបទពិសោធន៍ ដែលគាត់ត្រូវបានរំលោភបូក មុនពេលមានការរៀបចំរៀបអាពាហ៍ពិពាហ៍ឲ្យគាត់ ដែលបន្ទាប់មកគាត់ក៏ត្រូវបានបង្ខំឲ្យរួមដំណេកដោយការគំរាមដោយចុងកាំភ្លើងផងដែរ។ ការជំទាស់ ត្រូវបានលើកឡើងនៅសប្តាហ៍នេះ ពាក់ព័ន្ធទៅនឹងការដាក់បញ្ចូលនូវឯកសារថ្មីពីសំណុំរឿងលេខ០០៣ និង ០០៤ ក៏ដូចជា សំណើសុំរបស់អង្គជំនុំជម្រះសាលាដំបូង ធ្វើការកោះហៅសាក្សីថ្មី ក្នុងផ្នែកជំនុំជម្រះបន្ទាប់ ស្តីពីលក្ខណៈនៃជម្លោះប្រដាប់អាវុធ ។

Forges) និង **អានឌ្រូ ហ្គីចាហៅ** (Andrew Guichaoua) (ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៧) ឯកសារលេខ ICTR-98-44-T វាក្យខណ្ឌ ៣)។ សាក្សីជំនាញដែលបានផ្តល់សក្ខីកម្មមុននេះគឺ លោក **ហង់រី លោកាដ** (Henri LOCARD), លោក **អាឡិចហ្សង់ឌ័រ ហ៊ីនថុន** (Alexander HINTON), លោក **អ៊ីសា អូស្មាន់** (Ya OSMAN), លោកស្រី **អេលីហ្សាប៊ែត ប៊ែកឃើរ** (Elizabeth BECKER), លោក **រីឆាត ឌូដម៉ាន់** (Richard DUDMAN)។ សម្រាប់សេចក្តីសង្ខេបនៃការផ្តល់សក្ខីកម្មរបស់អ្នកជំនាញមុនៗ សូមមើល របាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ០២ លេខ៦១ ស្តីពីសវនាកាលើភស្តុតាង សប្តាហ៍ទី៥៨ (ចុះថ្ងៃទី ១ ដល់ ៤ សីហា ២០១៦), លេខ ៦០ ស្តីពីសវនាកាលើភស្តុតាង សប្តាហ៍ទី៥៧ (ចុះថ្ងៃទី២៦ ដល់២៩ ខែកក្កដា ឆ្នាំ២០១៦), លេខ ៤៨ ស្តីពីសវនាកាលើភស្តុតាង សប្តាហ៍ទី៤៥ (ចុះថ្ងៃទី២១ ដល់ ២៤ ខែមីនា ឆ្នាំ២០១៦), លេខ៤៧ ស្តីពីសវនាកាលើភស្តុតាង សប្តាហ៍ទី៤៤ (ថ្ងៃទី ១៤ ដល់ ១៧ ខែមីនា ឆ្នាំ២០១៦), លេខ៤៣ ស្តីពីសវនាកាលើភស្តុតាង សប្តាហ៍ទី៤០ (ចុះថ្ងៃទី ៩ដល់១០ ខែកុម្ភៈ ឆ្នាំ២០១៦), លេខ១៥ ស្តីពីសវនាកាលើភស្តុតាង សប្តាហ៍ទី១២ (ចុះថ្ងៃទី៣០ ខែមីនា ដល់ទី៣ ខែមេសា ឆ្នាំ២០១៥), លេខ ៨ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៥ (ចុះថ្ងៃទី៩ដល់១២ កុម្ភៈ ឆ្នាំ២០១៥)។

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ដាញ៉ែល ម៉ាធើស (Daniel Mattes) ខេតលីន កាហ្វហ្រ្វៀ (Caitlin McCaffrie), និន វុទ្ធី, តាយ លីណា, ធំ ស្ភាពរ និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែរឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University